ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
មន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ
វិទ្យាល័យសម្តេចអគ្គ ហ.ស. សំរោង

# អបអរសាទរទិវាជាតិអំណានលើកទី៥

## ១១ មីនា ២០២០

**អត្ថបទចូលរួមប្រឡងប្រណាំងតាក់តែងសិក្សាកថា**
**ក្រោមប្រធានបទ**




# តួនាទី ទស្សនាវដ្តីកម្ពុជសុរិយា ក្នុងការលើកកម្ពស់ អក្សរសិល្ប៍ខ្មែរ

# ប្រវត្តិរូបសង្ខេបបេក្ខជន

## ព័ត៌មានទូទៅ

- ឈ្មោះ : ឡុង ឆវង្ស
- ភេទ : ប្រុស
- សញ្ជាតិ : ខ្មែរ
- ថ្ងៃ ខែ ឆ្នាំកំណើត : ០៧ តុលា ១៩៩២
- ទីកន្លែងកំណើត : ខេត្តកំពង់ឆ្នាំង

## ការសិក្សា

- ឆ្នាំ២០១៦-២០១៩ : បរិញ្ញាបត្រជាន់ខ្ពស់ភាសាវិទ្យា (សាកលវិទ្យាល័យភូមិន្ទភ្នំពេញ)
- ឆ្នាំ២០១៧-២០១៨ : គរុនិស្សិតកម្រិតឧត្តម បរិញ្ញា+១ (វិទ្យាស្ថានជាតិអប់រំ)
- ឆ្នាំ២០១១-២០១៥ : បរិញ្ញាបត្រអក្សរសាស្ត្រខ្មែរ (សាកលវិទ្យាល័យភូមិន្ទភ្នំពេញ)

## អត្តភាពការងារ

- ឆ្នាំ២០១៨-បច្ចុប្បន្ន : គ្រូអក្សរសាស្ត្រខ្មែរ នៅវិទ្យាល័យសម្តេចអគ្គ ហ.ស. សំរោង

## ទំនាក់ទំនងបេក្ខជន


- ទូរស័ព្ទលេខ : ០៧៧ ៨៤០ ៧១១
- តេឡេក្រាម : ០៧៧ ៨៤០ ៧១១
- អ៊ីម៉ែល : chh.vong411@gmail.com

# មាតិកា

ទំព័រ


សេចក្ដីផ្ដើម ........ ១

១- ប្រវត្តិទស្សនាវដ្ដីកម្ពុជសុរិយា ........ ២

១.១- ព្រះរាជបណ្ណាល័យកម្ពុជា ........ ២

១.២- សាលាបាលីជាន់ខ្ពស់ ........ ២

១.៣- វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ........ ៣

១.៤- ទស្សនាវដ្ដីកម្ពុជសុរិយា ........ ៤

២- ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍ក្នុងទស្សនាវដ្ដីកម្ពុជសុរិយា ........ ៥

២.១- អ្នកនិពន្ធឬម្ចាស់អត្ថបទអក្សរសិល្ប៍នៃទស្សនាវដ្ដីកម្ពុជសុរិយា ........ ៦

២.២- ប្រភពអត្ថបទអក្សរសិល្ប៍ចុះក្នុងទស្សនាវដ្ដីកម្ពុជសុរិយា ........ ៨

២.៣- អត្ថរូបអត្ថបទអក្សរសិល្ប៍ចុះក្នុងទស្សនាវដ្ដីកម្ពុជសុរិយា ........ ៩

២.៤- ប្រភេទអត្ថបទអក្សរសិល្ប៍ចុះក្នុងទស្សនាវដ្ដីកម្ពុជសុរិយា ........ ១១

៣- តួនាទីទស្សនាវដ្ដីកម្ពុជសុរិយាក្នុងការលើកកម្ពស់អក្សរសិល្ប៍ខ្មែរ ........ ១៣

៣.១- តួនាទីផ្ដល់ឱកាសឱ្យអ្នកនិពន្ធបានចេញផ្សាយស្នាដៃ ........ ១៣

៣.២- តួនាទីផ្ដល់ការកម្សាន្តនិងចំណេះដឹងស្ដីអក្សរសិល្ប៍ ........ ១៤

៣.៣- តួនាទីអភិរក្ស ថែរក្សា និងលើកកម្ពស់វឌ្ឍនភាពអក្សរសិល្ប៍ខ្មែរ ........ ១៤

៤- សេចក្ដីសន្និដ្ឋាន ........ ១៥

ឯកសារពិគ្រោះ ........ ១៦

ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

មុនវត្តមានទស្សនាវដ្តីកម្ពុជសុរិយា អក្សរសិល្ប៍ខ្មែរស្ទើរតែទាំងស្រុងត្រូវបានបង្កប់ខ្លួនពួនជាប់នឹងមនុស្សខ្មែរ ជំនឿសាសនា ឬផ្តិតជាប់ជាមួយរូបចម្លាក់តាមជញ្ជាំងប្រាសាទ សិលាចារឹក និងគម្ពីរសាស្ត្រាស្លឹករឹត ជាដើម។ អត្ថបទអក្សរសិល្ប៍ទាំងនោះភាគច្រើនជាអក្សរសិល្ប៍បុរាណដែលខ្លឹមសារទទួលឥទ្ធិពលពីសាសនា(ព្រហ្មញ្ញសាសនានិងព្រះពុទ្ធសាសនា) និងដោយបានប្រើប្រាស់មធ្យោបាយតែងនិពន្ធជាកំណាព្យចារក្នុងសាស្ត្រាស្លឹករឹត ឆ្លាក់ជាចម្លាក់នៅជញ្ជាំងប្រាសាទឬគូរជាគំនូរនៅតាមជញ្ជាំងវិហារនៃវត្តអារាម។ ក្រៅពីនេះ ក៏នៅមានអក្សរសិល្ប៍មួយប្រភេទទៀតដែលបិតនៅជាប់ជិតស្និទ្ធជាមួយមនុស្សខ្មែរប្រជាជនខ្មែរ ដែលយើងហៅថាអក្សរសិល្ប៍ប្រជាប្រិយឬរឿងព្រេង។

នៅពាក់កណ្តាលសតវត្សទី១៩(ឆ្នាំ១៨៦០) រោងពុម្ពដែលជាមធ្យោបាយផ្សាយអត្ថបទបែបទំនើបបានចាប់កំណើតឡើងជាលើកដំបូងនៅឥណ្ឌូចិន(ហាណូយនិងព្រៃនគរ) ដែលបានបោះពុម្ពផ្សាយអត្ថបទសារព័ត៌មានជាភាសាបារាំងនិយាយអំពីសកម្មភាពអាណាព្យាបាលនៅឥណ្ឌូចិន និងដំណឹងផ្សេងៗពីប្រទេសកម្ពុជា។ ចំណែកអត្ថបទដែលបានផ្សាយជាពុម្ពអក្សរខ្មែរសរសេរជាអក្សរដៃត្រូវបានបោះពុម្ពលើកដំបូងនៅទីក្រុងប៉ារីសនាមុនឆ្នាំ១៨៧៧។ ក្រៅពីនេះ នៅឆ្នាំ១៨៨៩ក៏មានបង្កើតព្រឹត្តិបត្រមួយឈ្មោះ "ព្រឹត្តិបត្រផ្លូវការរបស់កម្ពុជា" (Bulletin officiel du Cambodge) ដែលបោះពុម្ពផ្សាយនៅព្រៃនគរ។ នៅក្នុងឆ្នាំ១៨៩០ រដ្ឋអំណាចបារាំងបានបង្កើតព្រឹត្តិបត្រមួយឈ្មោះថា "រូបថតខ្លះៗនៃប្រទេសកម្ពុជា" (Annuaire illustré du Cambodge) ដែលបានបោះពុម្ពផ្សាយលើកដំបូងនៅកម្ពុជា។ នៅឆ្នាំ១៨៩៩-១៩០០ កាសែតឯកជនដំបូងគេមួយឈ្មោះ "le petit Cambodgien" ក៏ត្រូវបានបង្កើតឡើង។ មកដល់ឆ្នាំ១៩១១ កាសែតផ្លូវការមួយទៀតមានឈ្មោះថា "រាជកិច្ច" សរសេរជាភាសាខ្មែរ ក៏ត្រូវបានកើតឡើងដែរ។ ចំណែកការបោះពុម្ពផ្សាយអត្ថបទអក្សរសិល្ប៍វិញ គេឃើញថាអត្ថបទអក្សរសិល្ប៍ទីមួយដែលបានបោះពុម្ពផ្សាយដំបូងគេនៅឆ្នាំ១៩០៨ គឺ "បណ្តាំតាមាស"។[1]

លុះក្រោយមកទៀតនៅឆ្នាំ១៩២៦ ទស្សនាវដ្តីកម្ពុសុរិយាក៏ចាប់កំណើតឡើងក្រោមដំបូលគ្រប់គ្រងរបស់ព្រះរាជបណ្ណាល័យកម្ពុជា ហើយបានប្រមូលនូវកម្រងអត្ថបទទាំងឡាយរបស់ខ្មែរដែលធ្លាប់មានព្រមទាំងបានស្រាវជ្រាវ រៀបរៀង បកប្រែ និងនិពន្ធអត្ថបទជាច្រើនដើម្បីធ្វើការបោះពុម្ពផ្សាយ ។ ចាប់តាំងពីកំណើតឡើងរហូតមកដល់បច្ចុប្បន្ននេះ កម្ពុជសុរិយានៅតែដើរតួនាទីសំខាន់និងសកម្មបំផុតនៅក្នុងការប្រមូលផ្តុំ ចងក្រង និងនិពន្ធអត្ថបទផ្សេងៗក្នុងបំណងផ្សាយចំណេះដឹងស្តីពីសាសនា ជំនឿ ប្រពៃណីទំនៀមទម្លាប់ វប្បធម៌ អរិយធម៌ អក្សរសាស្ត្រ អក្សរសិល្ប៍ រឿងព្រេង ប្រវត្តិសាស្ត្រ បុរាណវិទ្យា វេជ្ជសាស្ត្រជាដើម ដើម្បីបានជាប្រយោជន៍ទូទៅចំពោះជនជាតិខ្មែរ។

(1) សូមមើលបន្ថែម : ឃីង ហុកឌី, (២០០៧), *អក្សរសិល្ប៍ខ្មែរសតវត្សទី២០ (កវីនិពន្ធនិងកម្រងអត្ថបទ)*, ទំព័រ២២-២៦ : គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ។ និងសូមមើលផងដែរ Publishing in Cambodia, *Chapter 4 "The Print Media"* The Center for Khmer Studies, Reyum Institute & The Toyota Foundation, (December 2002)។

## ១- ប្រវត្តិទស្សនាវដ្តីកម្ពុជសុរិយា

មុននឹងលើកនិយាយអំពីប្រវត្តិនៃទស្សនាវដ្តីកម្ពុជសុរិយាថាមានដំណើរវិវត្តដូចម្តេចខ្លះនោះ គោងយើងត្រូវស្គាល់អំពីស្ថាប័នស្រាវជ្រាវសំខាន់ៗមួយចំនួនរបស់កម្ពុជានាពេលនោះ ដែលបានចាប់កំណើតឡើងមុនទស្សនាវដ្តីកម្ពុជសុរិយា និងជាឫសគល់ដ៏សំខាន់ដែលបានរួមចំណែកផ្តល់នូវវត្តមានដល់ទស្សនាវដ្តីនេះ។ ស្ថាប័នទាំងនោះរួមមានដូចជាព្រះរាជបណ្ណាល័យកម្ពុជា សាលាបាលីជាន់ខ្ពស់ និងវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ជាដើម។

### ១.១- ព្រះរាជបណ្ណាល័យកម្ពុជា(2)

កាលដើមឡើយស្ថាប័នមួយនេះមិនទាន់មានឈ្មោះហៅថា "ព្រះរាជបណ្ណាល័យ" ដូច្នេះនៅឡើយទេ។ យោងតាមរាជប្រកាសចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩២១ ស្ថាប័ននេះត្រូវបានបង្កើតឡើងក្រោមគំនិតផ្តួចផ្តើមរបស់រ៉េស៊ីដង់ជាន់ខ្ពស់បារាំង ហើយមានឈ្មោះហៅថា "ខេមរបណ្ណាល័យ"។ លុះ៤ឆ្នាំក្រោយមកពោលគឺនៅឆ្នាំ១៩២៥ យោងតាមរាជប្រកាសលេខ២ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩២៥ ស្ថាប័ននេះត្រូវបានប្តូរឈ្មោះពី "ខេមរបណ្ណាល័យ" មកជា "ព្រះរាជបណ្ណាល័យ" ដោយឋិតក្រោមអាណាព្យាបាលភាពរបស់ព្រះរាជាខ្មែរនិងរ៉េស៊ីដង់ជាន់ខ្ពស់បារាំងនៅកម្ពុជា។ រហូតមកដល់ ឆ្នាំ១៩៤៣ ព្រះរាជប្រកាសមួយត្រូវបានចេញផ្សាយដើម្បីប្រែឈ្មោះពី "ព្រះរាជបណ្ណាល័យ" មកជា "បណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ"។

បន្ទាប់ពីព្រះរាជបណ្ណាល័យត្រូវបានបង្កើតឡើងនៅក្រុងភ្នំពេញ គេឃើញបណ្តាខេត្តផ្សេងៗ ក្នុងនោះមានជាអាទិ៍ខេត្តបាត់ដំបងនិងខេត្តកំពង់ចាមបានយកឯកសារ គម្ពីរសាស្ត្រា និងរបស់របរផ្សេងៗមកប្រគល់ជូនព្រះរាជបណ្ណាល័យ។ ព្រះរាជបណ្ណាល័យបានដើរតួនាទីជាអ្នកប្រមូល និពន្ធចងក្រង ថែរក្សា និងបោះពុម្ពផ្សាយឯកសារផ្សេងៗដែលទាក់ទងទៅនឹងទំនៀមទម្លាប់ ប្រពៃណី និងវិស័យព្រះពុទ្ធសាសនាដើម្បីបានជាប្រយោជន៍ទូទៅសម្រាប់នគរកម្ពុជា។ ទន្ទឹមនេះ វត្តមាននៃព្រះរាជបណ្ណាល័យក៏បានជួយសម្រួលដល់ការសិក្សាវិស័យព្រះពុទ្ធសាសនរបស់ព្រះសង្ឃបរិយត្តជាន់ខ្ពស់ថែមទៀត។ លើសពីនេះទៅទៀត នៅក្នុងឆ្នាំ១៩២៦ព្រះរាជបណ្ណាល័យបានផ្តួចផ្តើមបង្កើតឱ្យមាននូវទស្សនាវដ្តីកម្ពុជសុរិយា ដែលជាទស្សនាវដ្តីភាសាខ្មែរចេញផ្សាយលើកដំបូងគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ១.២- សាលាបាលីជាន់ខ្ពស់(3)

នៅក្នុងរាជ្យព្រះបាទស៊ីសុវត្ថិ សាលាបាលីដំបូងគេនៅព្រះរាជាណាចក្រកម្ពុជាមានឈ្មោះថា "បរមពុទ្ធវចនបរិយត្តិបាសាន" ត្រូវបានបង្កើតឡើងនៅនគរវត្ត (ខេត្តសៀមរាប) ដោយព្រះរាជប្រកាសចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩០៩ ដែលមានព្រះពុទ្ធវង្ស អ៊ឹង ទេពម៉ី ជាចាងហ្វាង។ ប៉ុន្តែដោយសារតែទីតាំងនៅឆ្ងាយពីក្រុងដែលនាំឱ្យមានដំណើរការមិនល្អ សាលានេះក៏បានបិទទៅវិញនៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ១៩១១។ លុះដល់ឆ្នាំ១៩១៤ សាលាបាលីមួយទៀតត្រូវបានបង្កើតឡើងនៅភ្នំពេញ ហើយមានឈ្មោះថា "បរមពុទ្ធវចនបរិយត្តមន្ទីរ" តាមប្រកាសលេខ៨៥ ចុះនៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩១៤ និងបានចាប់ផ្តើមសម្ពោធនៅ

---

(2) ពុទ្ធសាសនបណ្ឌិត្យ, (២០០៥), *ប្រវត្តិសង្ខេបពុទ្ធសាសនបណ្ឌិត្យ*, ទំព័រ១២-១៨។

(3) ពុទ្ធសាសនបណ្ឌិត្យ, (២០០៥), *ប្រវត្តិសង្ខេបពុទ្ធសាសនបណ្ឌិត្យ*, ទំព័រ១៨-២០។

ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩១៥ ក្រោមព្រះរាជាធិបតីព្រះករុណាស៊ីសុវត្ថិនិងតំណាងរដ្ឋការបារាំង។ តាមព្រះរាជក្រឹត្យលេខ២៦៥ ន.ស. ចុះថ្ងៃទី១៨ ឧសភា ឆ្នាំ១៩៥៥ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ត្រាស់បង្គាប់សាលាបាលីជាន់ខ្ពស់ និងមាននាមថា "គ្រឹះស្ថានមធ្យមសិក្សានៃពុទ្ធសាសនា"។ ក្រោយមកបានប្រែឈ្មោះថា "ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត" តាមព្រះរាជក្រឹត្យលេខ៣៨៨ ន.ស. ចុះថ្ងៃទី៤ កក្កដា ១៩៥៥ (នៅក្រោយពេលដែលពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជកើតឡើង)។[4]

សាលាបាលីជាន់ខ្ពស់នេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងទប់ស្កាត់ការនិមន្តរបស់ព្រះសង្ឃខ្មែរដែលមានបំណងទៅសិក្សាព្រះត្រៃបិដកនៅប្រទេសសៀម។ ក្រៅពីនេះ ស្ថាប័នមួយនេះបានបណ្តុះបណ្តាលបញ្ញវន្តសង្ឃជាច្រើន និងថែមទាំងជាកន្លែងដែលប្រមូលផ្តុំអ្នកប្រាជ្ញខ្មែរខាងសាសនាជាតិដើម្បីធ្វើការនិពន្ធចងក្រងសៀវភៅ អត្ថបទជាភាសាបាលីនិងភាសាខ្មែរ ជាពិសេសព្រះត្រៃបិដក។ បញ្ញវន្តសង្ឃនិងអ្នកប្រាជ្ញខ្មែរជាច្រើនរូបដែលធ្លាប់បានបំពេញនាទីជាសាស្ត្រាចារ្យនិងធ្លាប់បានសិក្សារៀនសូត្រនៅក្នុងស្ថាប័ននេះក៏បានយកចំណេះទាំងនោះទៅបង្រៀនបន្តនៅតាមសាលាបាលីរងនានាក្នុងវត្តរបស់ខ្លួន ហើយបាននិពន្ធចងក្រង និងបកប្រែអត្ថបទផ្សេងៗចុះផ្សាយក្នុងទស្សនាវដ្តីកម្ពុជសុរិយា ទស្សនាវដ្តីពន្លឺពុទ្ធចក្រ និងទស្សនាវដ្តីមិត្តសាលាបាលី ជាដើម។

## ១.៣- វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ[5][6]

ក្រោមគំនិតផ្តួចផ្តើមរបស់ព្រះគ្រូសង្ឃវិជ្ជា ហួត តាត កញ្ញាកាប៉ឺឡែស លោកអគ្គទេសាភិបាល និងទេសាភិបាលបារាំង ស្ថាប័នមួយនេះត្រូវបានបង្កើតឡើងនៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៣០ មានឈ្មោះហៅថា "មន្ទីរពុទ្ធសាសនបណ្ឌិត្យ" មានទីចាត់ការនៅក្នុងបរិវេណព្រះរាជបណ្ណាល័យ។ កញ្ញាកាប៉ឺឡែស ដែលជាជនជាតិដើមជ្វីស មានសញ្ជាតិបារាំង ត្រូវបានតែងតាំងជាអគ្គលេខាធិការដំបូងគេដើម្បីគ្រប់គ្រងនិងមើលការខុសត្រូវមន្ទីរនេះ។ ក្រៅពីមានឈ្មោះហៅថា "មន្ទីរពុទ្ធសាសនបណ្ឌិត្យ" ដូចនេះ ស្ថាប័នមួយនេះក៏ត្រូវបានគេហៅឈ្មោះប្លែកៗពីគ្នាផងដែរដូចជា ខ្លះហៅថា "ក្រុមពុទ្ធសាសនបណ្ឌិត្យ" ឯខ្លះទៀតហៅ "ក្រសួងពុទ្ធសាសនបណ្ឌិត្យ" និងខ្លះទៀតហៅខ្លីត្រឹមតែ "ពុទ្ធសាសនបណ្ឌិត្យ"។ ប៉ុន្តែមកទល់នឹងពេលបច្ចុប្បន្ននេះ ស្ថាប័នមួយនេះមានឈ្មោះហៅជាផ្លូវការថា "វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ"។

នៅក្នុងសម័យអាណាព្យាបាលបារាំងនិងសម័យសង្គមរាស្ត្រនិយម ស្ថាប័នពុទ្ធសាសនបណ្ឌិត្យទទួលបានការឧបត្ថម្ភគាំទ្រពីរដ្ឋការនិងរដ្ឋាភិបាល។ ការបង្កើតពុទ្ធសាសនបណ្ឌិត្យគឺមានគោលបំណងធ្វើឱ្យពុទ្ធសាសនិកនៅក្នុងឥណ្ឌូចិន-បារាំងមានការរួបរួមគ្នានិងជួយឱ្យមានការប្រតិបត្តិរបៀបរបស់អ្នកស្រុក។ ទន្ទឹមនឹងនេះ ពុទ្ធសាសនបណ្ឌិត្យក៏បានក្លាយជាមន្ទីរសម្រាប់អ្នកប្រាជ្ញពុទ្ធសាសនានៅឥណ្ឌូចិន និងជាមន្ទីរទស្សនកិច្ចផ្លូវរដ្ឋសម្រាប់មន្ត្រីអាណាព្យាបាលនិងភ្ញៀវនៃប្រទេសក្នុងដែនដីឥណ្ឌូចិនផងដែរ។ ស្ថាប័នពុទ្ធសាសនបណ្ឌិត្យបានដើរតួនាទីជាមជ្ឈមណ្ឌលបណ្តុះបណ្តាល សិក្សាស្រាវជ្រាវ ប្រមូលចងក្រង និពន្ធ

---

(4) សូមអាន : វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ២០០៦, *ប្រវត្តិពុទ្ធិកសិក្សា* : ទំព័រ៣៥។

(5) ពុទ្ធសាសនបណ្ឌិត្យ, (២០០៥), *ប្រវត្តិសង្ខេបពុទ្ធសាសនបណ្ឌិត្យ*, ទំព័រ២១-៤៨។

(6) https://m.youtube.com/watch?v=xS8jDr2Io0E វីដេអូសម្រាប់បុណ្យខួបទី៩០ឆ្នាំនៃការបង្កើតពុទ្ធសាសនបណ្ឌិត្យ។

និងបានបោះពុម្ពផ្សាយឯកសារជាច្រើនដូចជាផ្នែកសាសនា សីលធម៌ ប្រពៃណី ទំនៀមទម្លាប់ វប្បធម៌ អរិយធម៌ អក្សរសាស្ត្រ ប្រវត្តិសាស្ត្រ សិល្បៈ បុរាណវិទ្យា គម្ពីរព្រះត្រៃបិដក សាស្ត្រាស្លឹករឹត រឿងព្រេង និងទស្សនាវដ្ដីកម្ពុជសុរិយា ជាដើម។

នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) ពុទ្ធសាសនបណ្ឌិត្យត្រូវបានបិទទ្វារមិនដំណើរការ ហើយជំនឿសាសនាផ្នែកប្រតិបត្តិត្រូវបានហាមឃាត់។ ក្រោយពេលរបបនេះត្រូវបានផ្ដួលរំលំដំណើរការពុទ្ធសាសនបណ្ឌិត្យក៏ពុំទាន់ត្រូវបានស្ដារឡើងវិញភ្លាមដែរ។ លុះក្រោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសពោលគឺនៅឆ្នាំ១៩៩២ ពុទ្ធសាសនបណ្ឌិត្យបានចាប់បដិសន្ធិឡើងជាលើកទី២នៅពេលដែលរដ្ឋសភាកម្ពុជាបានអនុម័តច្បាប់បង្កើតឱ្យមានក្រសួងធម្មការឡើងវិញ។ ចាប់ពីពេលនោះមក វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យបានបន្តតួនាទីនិងស្ដារឡើងវិញនូវភាពរុងរឿងរបស់ខ្លួនដែលធ្លាប់មានពីអតីតកាល។ ក្រោយដំណើរការឡើងវិញនៅឆ្នាំ១៩៩២មកដល់បច្ចុប្បន្ន ស្ថាប័នមួយនេះបានបើកទ្វារទទួលជំនួយគាំទ្រពីអាល្លឺម៉ង់និងជប៉ុន(អង្គការសាសនានិងមនុស្សធម៌ជប៉ុន)។ យោងតាមអនុក្រឹត្យលេខ១៥៤ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ការងារសំខាន់ៗនិងធំៗមួយចំនួនរបស់ពុទ្ធសាសនបណ្ឌិត្យមានដូចជា ការបើកឱ្យដំណើរការបណ្ណាល័យ ការបន្តចងក្រងនិងបោះពុម្ពផ្សាយទស្សនាវដ្ដីកម្ពុជសុរិយា ការរៀបចំបាឋកថាប្រចាំខែ ការរៀបចំធ្វើសិក្ខាសាលាប្រពៃណីទំនៀមទម្លាប់ប្រចាំឆ្នាំ និងការរៀបចំឱ្យមាននូវកម្មវិធីប្រឡងពានរង្វាន់អក្សរសិល្ប៍ពុទ្ធសាសនបណ្ឌិត្យ ជាដើម។

### **១.៤- ទស្សនាវដ្ដីកម្ពុជសុរិយា**[7]

កម្ពុជសុរិយា ជាពាក្យបាលី ដែលប្រែសម្រាយសេចក្ដីជាភាសាខ្មែរមានន័យថា "ព្រះអាទិត្យកម្ពុជា" ហើយក៏ជាឈ្មោះទស្សនាវដ្ដីដែលបានផ្ដួចផ្ដើមបង្កើតឡើងដំបូងដោយព្រះរាជបណ្ណាល័យកម្ពុជានៅក្នុងឆ្នាំ១៩២៦។ ការសន្មតឈ្មោះហៅថា "ទស្សនាវដ្ដីកម្ពុជសុរិយា" នោះដោយលោកអ្នកបង្កើតមានសេចក្ដីយល់ឃើញថា ប្រទេសកម្ពុជាចាប់ពីពេលដែលមានទស្សនាវដ្ដីនេះចេញផ្សាយតាមមុខការខាងជួយបំភ្លឺពន្យល់គតិលោក គតិធម៌ ទុកដូចជាមានព្រះអាទិត្យមួយរះបញ្ចាំងរស្មីភ្លឺត្រចះ ហើយបណ្ដាជនជាតិខ្មែរក៏នឹងកើតមានប្រាជ្ញាភ្លឺស្វាងក្នុងផ្លូវលោក ផ្លូវធម៌ ដោយសារបានអានទស្សនាវដ្ដីនេះ។ កម្ពុជសុរិយាគឺជាទស្សនាវដ្ដីដែលចេញផ្សាយរាល់ខែពីចន្លោះឆ្នាំ១៩២៦-១៩៧៤ (ក្នុងនោះចាប់ពីឆ្នាំ១៩២៦-១៩៤២ បានផ្សាយចេញពីព្រះរាជបណ្ណាល័យកម្ពុជា ដោយមានការអនុញ្ញាតពីគណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ និងចាប់ពីឆ្នាំ១៩៤៣-១៩៧៤ បានផ្សាយចេញពីវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ) និងចេញផ្សាយរាល់ត្រីមាសចាប់ពីឆ្នាំ១៩៩៤មកទល់នឹងបច្ចុប្បន្ននេះ(ផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ)។

រាប់តាំងពីឆ្នាំបង្កើតឡើងដំបូងនៅឆ្នាំ១៩២៦រហូតដល់ឆ្នាំ១៩៤២ ពោលគឺអំឡុងពេលដែលឋិតនៅក្រោមការគ្រប់គ្រងរបស់ព្រះរាជបណ្ណាល័យកម្ពុជា កម្ពុជសុរិយាបានចេញផ្សាយទស្សនាវដ្ដីដល់ឆ្នាំទី១៥ និងសរុបចំនួន១៦៧លេខ។[8] គ្រាដែលបោះពុម្ពផ្សាយនាឆ្នាំដំបូងៗ យើងពិនិត្យឃើញថា កម្ពុជសុរិយាបាន

---

(7) ឃួរ អ៊ុន, (១៩៥៨), *ប្រវត្តិនៃទស្សនាវដ្ដីកម្ពុជសុរិយា*, កម្ពុជសុរិយាឆ្នាំទី៣០ លេខ១០ ខែតុលា : ទំព័រ៩៣៣។

(8) សូមមើលទិន្នន័យក្នុងតារាងឧបសម្ព័ន្ធ១ : *កម្ពុជសុរិយាឆ្នាំ១៩២៦-១៩៤២*។

ផ្សាយនូវអត្ថបទខាងគតិធម៌ អត្ថបទសាសនា ច្រើនជាងអត្ថបទខាងគតិលោក។ ការណ៍នេះបូករួមនិងមតិពីអ្នកអានភាគច្រើនផង ទើបចាប់ពីឆ្នាំ១៩២៨មក ព្រះរាជបណ្ណាល័យកម្ពុជាបានចុះផ្សាយអត្ថបទខាងគតិលោកច្រើនជាងខាងគតិធម៌វិញម្តង។[(9)] ជាបន្តមកទៀត ពីឆ្នាំ១៩៤៣រហូតដល់ឆ្នាំ១៩៧៤ កម្ពុជសុរិយានៅតែបន្តតួនាទីរបស់ខ្លួននិងកាន់តែខិតខំប្រឹងប្រែងនៅក្នុងការចេញផ្សាយទស្សនាវដ្តីប្រចាំខែ ដែលមានពីឆ្នាំទី១៥ដល់ឆ្នាំទី៤៦ និងសរុបមានចំនួន៣១៦លេខ។[(10)] លុះចាប់ពីឆ្នាំ១៩៩៤ដល់ឆ្នាំ២០០៦ និងចាប់ពីឆ្នាំ២០១៤ដល់ឆ្នាំ២០១៩ កម្ពុជសុរិយាបានចេញផ្សាយទស្សនាវដ្តីប្រចាំត្រីមាស ដែលក្នុងមួយឆ្នាំចេញផ្សាយ៤លេខ ចន្លោះពីឆ្នាំទី៤៨ដល់ឆ្នាំទី៦៦ ហើយរាប់សរុបមានចំនួន៧៦លេខ។[(11)]

ប្រសិនយើងពិនិត្យជារួមឬយោងតាមបញ្ជីរឿង(មាតិកា)នៃទស្សនាវដ្តីកម្ពុជសុរិយា យើងនឹងឃើញថា ទស្សនាវដ្តីនេះបានចែកទម្រង់មាតិកាជា៣ផ្នែកធំៗគឺៈ

១- *ផ្នែកសាសនា* : កម្ពុជសុរិយាបានចុះផ្សាយជាប្រចាំខែឬក៏ប្រចាំត្រីមាសនូវអត្ថបទខាងសាសនា ជាពិសេសគឺពុទ្ធសាសនា ដែលមានក្នុងគម្ពីរស្លឹករឹត ការប្រែពីគម្ពីរឬជាតកផ្សេងៗ ឬបទនិពន្ធថ្មីដោយយោលលើខ្លឹមសារទ្រឹស្តីពុទ្ធសាសនា និងព្រមទាំងដំណឹងជាគតិធម៌ផ្សេងៗ ដែលអត្ថបទទាំងនោះមួយចំនួនធំសុទ្ធសឹងកើតមកអំពីស្នាព្រះហស្ថរបស់អ្នកប្រាជ្ញជាព្រះសង្ឃ អាចារ្យ បញ្ញវន្ត និងក្រុមបុគ្គលិកក្នុងស្ថាប័នពុទ្ធសាសនបណ្ឌិត្យដែលមានចំណេះចេះដឹងជ្រៅជ្រះផ្នែកសាសនា។

២- *ផ្នែកអក្សរសាស្ត្រ* : កម្ពុជសុរិយាបានចុះផ្សាយនូវអត្ថបទខាងអក្សរសាស្ត្រ អក្សរសិល្ប៍ រឿងព្រេង ប្រពៃណីទំនៀមទម្លាប់ វប្បធម៌ អរិយធម៌ ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ វេជ្ជសាស្ត្រ និងកម្រងជីវប្រវត្តិ។ល។ ដែលអត្ថបទទាំងនេះមួយចំនួនធំកើតមកពីក្រុមបុគ្គលិកនៃពុទ្ធសាសនបណ្ឌិត្យ និងមួយចំនួនទៀតប្រមូលបានឬទទួលបានពីមជ្ឈដ្ឋានអ្នកនិពន្ធ អ្នកសិក្សាស្រាវជ្រាវ និងមហាជនទូទាំងប្រទេសដែលបានផ្ញើអត្ថបទមកឱ្យកម្ពុជសុរិយាជួយពិនិត្យនិងចុះផ្សាយ។

៣- *ផ្នែកប្រវត្តិការណ៍និងដំណឹងផ្សេងៗ* : នៅខាងចុងលេខនីមួយៗនៃទស្សនាវដ្តីកម្ពុជសុរិយា តែងបានភ្ជាប់ទៅជាមួយនូវកូនអត្ថបទខ្លីៗ ដែលបិតក្នុងទម្រង់ជាដំណឹងផ្សេងៗដើម្បីជម្រាបឬជាសារដល់អ្នកអាន អ្នកជាវ អំពីការប្រព្រឹត្តទៅរបស់កម្ពុជសុរិយា ឬក៏អធិប្បាយពីសកម្មភាពផ្សេងៗរបស់ក្រុមដែលធ្វើទស្សនាវដ្តីនេះ។

## ២- ទិដ្ឋភាពទូទៅនៃអក្សរសិល្ប៍ក្នុងទស្សនាវដ្តីកម្ពុជសុរិយា

ចំពោះទិដ្ឋភាពផ្សេងៗទាក់ទងនឹងអត្ថបទអក្សរសិល្ប៍ ដែលចុះផ្សាយក្នុងទស្សនាវដ្តីកម្ពុជសុរិយា យើងនឹងលើកមកបង្ហាញដោយបែងចែកជា៤ចំណុចសំខាន់ៗ[(12)]គឺ ទី១និយាយពី "អ្នកនិពន្ធឬម្ចាស់អត្ថបទអក្សរសិល្ប៍នៃទស្សនាវដ្តីកម្ពុជសុរិយា" ទី២និយាយពី "ប្រភពនៃអត្ថបទអក្សរសិល្ប៍ដែលចុះក្នុងទស្សនាវដ្តី

(9) សូមមើលបន្ថែម : ឌឹក គាម, (១៩៦៦), *ឯកសារកម្ពុជសុរិយាឆ្នាំ១៩២៦-១៩៦៥* : កម្ពុជសុរិយាឆ្នាំទី៣៨-៤០។

(10) សូមមើលទិន្នន័យក្នុងតារាងឧបសម្ព័ន្ធទី១ : *កម្ពុជសុរិយាឆ្នាំ១៩៤៣-១៩៧៤*។

(11) សូមមើលទិន្នន័យក្នុងតារាងឧបសម្ព័ន្ធទី១ : *កម្ពុជសុរិយាឆ្នាំ១៩៩៤-២០០៦* និង *កម្ពុជសុរិយាឆ្នាំ២០១៤-២០១៩*។

(12) យោងតាមទិន្នន័យដែលស្រង់បានចំនួន ៧៤៤ ចំណងជើងអត្ថបទ(អត្ថបទដែលរាប់ជាស្នាដៃអក្សរសិល្ប៍)។ សូមមើលក្នុងតារាងឧបសម្ព័ន្ធ២។

កម្ពុជសុរិយា” ទី៣និយាយពី “អត្ថរូបនៃអត្ថបទអក្សរសិល្ប៍ដែលចុះក្នុងទស្សនាវដ្តីកម្ពុជសុរិយា” និងទី៤និយាយពី “ប្រភេទអត្ថបទអក្សរសិល្ប៍ដែលចុះក្នុងទស្សនាវដ្តីកម្ពុជសុរិយា”។

## ២.១- អ្នកនិពន្ធឬម្ចាស់អត្ថបទអក្សរសិល្ប៍នៃទស្សនាវដ្ដីកម្ពុជសុរិយា

នៅក្នុងទិដ្ឋភាពរួមមួយ អ្នកនិពន្ធដែលបានចាប់កំណើតឡើងនៅចុងសតវត្សទី១៩និងដើមសតវត្សទី២០ អត្ថបទរបស់ពួកគាត់ត្រូវបានគេប្រមូលយកមកផ្សាយឬចុះផ្សាយក្នុងទស្សនាវដ្ដីកម្ពុជសុរិយាចាប់ពីចន្លោះឆ្នាំ១៩២៦ ដល់ឆ្នាំ១៩៤២ ដែលភាគច្រើនសុទ្ធសឹងជាព្រះសង្ឃឬបុគ្គលដែលធ្លាប់បានបួសរៀនមានចំណេះចេះដឹងជ្រៅជ្រះក្នុងសំណាក់ពុទ្ធសាសនា ជាសាស្ត្រាចារ្យនៅសាលាបាលីជាន់ខ្ពស់ឬជាសមាជិករបស់ក្រុមជំនុំទំនៀមទម្លាប់។ ចំពោះអត្ថបទដែលបានចុះផ្សាយចាប់ពីឆ្នាំ១៩៤៣ដល់ឆ្នាំ១៩៧៤ គឺចេញមកអំពីអ្នកនិពន្ធដែលចាប់កំណើតឡើងនៅដើមសតវត្សទី២០រហូតដល់ជិតពាក់កណ្ដាលទីមួយនៃសតវត្សទី២០។ ចំណែកអត្ថបទដែលបានចុះផ្សាយចាប់ពីឆ្នាំ១៩៩៤ដល់ឆ្នាំ២០១៩ មានអ្នកនិពន្ធដែលចាប់កំណើតឡើងចាប់ពីពាក់កណ្ដាលសតវត្សទី២០និងចុងសតវត្សទី២០។

អ្នកនិពន្ធឬម្ចាស់អត្ថបទអក្សរសិល្ប៍(13) ដែលបានចុះផ្សាយអត្ថបទរបស់ខ្លួនឬត្រូវបានគេប្រមូលស្នាដៃរបស់ពួកគាត់មកចុះក្នុងទស្សនាវដ្ដីកម្ពុជសុរិយា គឺប្រសូតចេញមកពីមជ្ឈដ្ឋានផ្សេងៗគ្នានៃធនធានមនុស្សតាមដំណាក់កាលនៃសង្គមខ្មែរ រាប់ចាប់តាំងពីទស្សនាវដ្ដីនេះបានចាប់កំណើតឡើងមកទល់នឹងពេលបច្ចុប្បន្ននេះ។ ប្រភពអ្នកនិពន្ធឬម្ចាស់អត្ថបទអក្សរសិល្ប៍ទាំងនោះមានដូចជា មន្ត្រីឬបុគ្គលិកស្ថាប័នពុទ្ធសាសនបណ្ឌិត្យ ព្រះសង្ឃ/សមណសិស្ស-និស្សិត/អាចារ្យ អ្នកនិពន្ធឬអ្នកសិក្សាស្រាវជ្រាវ សាធារណជន ព្រះមហាក្សត្រនិងមន្ត្រីធំ និងមន្ត្រីរាជការទូទៅ ផងដែរ។ ក្រៅអំពីនេះមានបណ្ដាអ្នកនិពន្ធឬម្ចាស់អត្ថបទមួយចំនួនទៀតដែលយើងមិនបានស្គាល់ប្រភពសាវតារច្បាស់លាស់ ឬយើងខិតខំរកព័ត៌មានដែរប៉ុន្តែមិនទាន់ទទួលបាន(14) ដូច្នេះយើងសូមរាប់បញ្ចូលនៅក្នុងផ្នែកផ្សេងៗ។ យោងតាមប្រភពទិន្នន័យដែលបានស្រង់និងបានផ្ទៀងផ្ទាត់ យើងទទួលបានលទ្ធផលទាក់ទងនឹងអ្នកនិពន្ធឬម្ចាស់អត្ថបទអក្សរសិល្ប៍ក្នុងទស្សនាវដ្ដីកម្ពុជសុរិយាដូចខាងក្រោម៖

- អ្នកនិពន្ធឬម្ចាស់អត្ថបទដែលជាមន្ត្រីឬបុគ្គលិកស្ថាប័នពុទ្ធសាសនបណ្ឌិត្យ ហើយដែលបាននិពន្ធរៀបរៀង ចងក្រងចុះផ្សាយអត្ថបទមានចំនួនប្រមាណ ៤៣ រូប និងបានចុះផ្សាយអត្ថបទអក្សរសិល្ប៍បានចំនួន ២៥២ ស្នាដៃ ត្រូវជា ៣៥% នៃស្នាដៃអក្សរសិល្ប៍ទាំងអស់ដែលមានក្នុងទស្សនាវដ្ដីនេះ។ យើងពិនិត្យឃើញថា អត្ថបទដែលក្រុមនេះស្ដែងចេញភាគច្រើនគឺជាប្រភេទរឿងព្រេងដែលបានពីការធ្លាប់ចេះចាំឬការសាកសួរចាស់ទុំនៅតាមបណ្ដាស្រុកផ្សេងៗនៃព្រះរាជាណាចក្រ និងអត្ថបទនិយាយពីជំនឿ ប្រពៃណី ទំនៀមទម្លាប់ ហើយក៏មានមួយភាគទៀតជាអត្ថបទដែលទាក់ទងនឹង

(13) នៅទីនេះស្នេរសូមប្រើពាក្យ “អ្នកនិពន្ធឬម្ចាស់អត្ថបទ” ដោយរាប់បញ្ចូលទាំងអ្នកដែលបាននិពន្ធ អ្នកបកប្រែ ឬអ្នកចម្លងឡើងវិញ ក៏ដោយ។

(14) ការដែលយើងមិនបានស្គាល់ប្រភពសាវតារឬព័ត៌មានរបស់អ្នកនិពន្ធឬម្ចាស់អត្ថបទមួយចំនួនបានច្បាស់លាស់ មូលហេតុចម្បងគឺក្នុងស្នាដៃមិនបានដាក់ប្រភពច្បាស់លាស់។ ទីទៃពីនេះគឺ ទី១ដោយសារតែឈ្មោះម្ចាស់អត្ថបទអក្សរសិល្ប៍ដែលផ្សាយក្នុងទស្សនាវដ្ដីនេះមានចំនួនច្រើននិងមកពីច្រើនមជ្ឈដ្ឋាន។ ទី២មកអំពីការចំណាយពេលវេលាច្រើនទៅលើការស្រង់ទិន្នន័យរួមទាំងការចុះកូដផ្សេងៗដើម្បីធ្វើចំណាត់ថ្នាក់ទិន្នន័យ។ និងទី៣ដោយសារតែការមមាញឹកក្នុងអាជីពជាមន្ត្រីរាជការនិងបញ្ហាជីវភាពរស់នៅប្រចាំថ្ងៃ។

សាសនា។ អ្នកដែលបានបញ្ចេញអត្ថបទផ្នែកអក្សរសិល្ប៍ច្រើនស្នាដៃជាងគេគឺ យុនបណ្ណានុរក្ស ប៊ូ-ប៉ូ ដោយអត្ថបទទាំងឡាយរបស់លោកបានលើកពីរឿងចម្រុះបែប។

- អ្នកនិពន្ធឬម្ចាស់អត្ថបទដែលជាព្រះសង្ឃ/សមណសិស្ស-និស្សិត/អាចារ្យ មានចំនួនប្រមាណ៦២រូប និងបានចុះផ្សាយអត្ថបទអក្សរសិល្ប៍បានចំនួន ១១៣ ស្នាដៃ ត្រូវជា១៥%នៃស្នាដៃអក្សរសិល្ប៍ក្នុងកម្ពុជសុរិយា។ ធនធាននៅក្នុងក្រុមនេះ ភាគច្រើនគឺជាសាស្ត្រាចារ្យឬសមណសិស្ស-និស្សិតនៅសាលាបាលីជាន់ខ្ពស់ សាលាបាលីរង ឬជាសមាជិកក្រុមជំនុំទំនៀមទម្លាប់ ជាដើម។ ចំណែកឯខ្លឹមសារស្នាដៃ ភាគច្រើនទាក់ទងទៅនឹងសាសនា(ព្រះពុទ្ធសាសនា)ដែលជាការប្រែពីគម្ពីរផ្សេងៗនៃពុទ្ធសាសនា ឬឃោលលើការអប់រំផ្នែកសីលធម៌សង្គម។ ចំណោមបញ្ញវន្តស្រទាប់នេះ អ្នកដែលបានបញ្ចេញអត្ថបទច្រើនជាងគេគឺ ភិក្ខុ ម៉ែន រៀម ដែលស្នាដៃរបស់ព្រះអង្គភាគច្រើនជារឿងព្រេងបកប្រែពីបណ្ដាប្រទេសផ្សេងៗ។
- អ្នកនិពន្ធឬម្ចាស់អត្ថបទដែលមានអាជីពជាអ្នកនិពន្ធឬអ្នកស្រាវជ្រាវ មានចំនួនប្រមាណ២៦រូប និងបានចុះផ្សាយអត្ថបទអក្សរសិល្ប៍បានចំនួន ៥៤ ស្នាដៃ ត្រូវជា១០%នៃស្នាដៃអក្សរសិល្ប៍ក្នុងកម្ពុជសុរិយា។ នៅក្នុងក្រុមនេះ យើងពិនិត្យឃើញថាទំនោរនៃការតែងនិពន្ធចាប់ផ្ដើមមានរបត់បណ្ដើរៗដោយងាកពីការផ្ដោតលើខ្លឹមសារសាសនាឬទំនៀមទម្លាប់ ពោលគឺមកនិយាយពីរឿងរ៉ាវនៃជីវភាពរស់នៅជាក់ស្ដែងឬការអប់រំក្រើនរំឭកមនុស្សក្នុងសង្គមវិញម្ដង។ ចំពោះបញ្ញវន្តនៅក្នុងស្រទាប់នេះ អ្នកដែលបានចេញផ្សាយអត្ថបទរបស់ខ្លួនច្រើនជាងគេគឺ អ្នកព្រះភិរម្យភាសាអ៊ូហៅ ង៉ុយ ដែលស្នាដៃរបស់លោកភាគច្រើនជាច្បាប់ឧបទេស និងម្នាក់ទៀតគឺអ្នកនិពន្ធ សាង សារ៉ាត ដែលស្នាដៃរបស់លោកក្នុងទស្សនាវដ្ដីនេះច្រើនជាអត្ថបទរឿងនិទានខ្លីៗ។
- អ្នកនិពន្ធឬម្ចាស់អត្ថបទដែលជាសាធារណជនទូទៅ បានចុះផ្សាយអត្ថបទអក្សរសិល្ប៍បានចំនួន ៥៤ស្នាដៃ ត្រូវជា៧% នៃអត្ថបទអក្សរសិល្ប៍ក្នុងកម្ពុជសុរិយា ភាគច្រើនជាកូនអត្ថបទខ្លីៗក្នុងទម្រង់ជាកំណាព្យ ឬការនិទានពីប្រវត្តិស្ថាននាមផ្សេងៗដែលពួកគាត់បានចេះចាំ។
- អ្នកនិពន្ធឬម្ចាស់អត្ថបទដែលជាព្រះមហាក្សត្រឬមន្ត្រីធំៗ បានចុះផ្សាយអត្ថបទអក្សរសិល្ប៍ចំនួន ៤៣ស្នាដៃ ត្រូវជា៦%នៃអត្ថបទអក្សរសិល្ប៍ក្នុងកម្ពុជសុរិយា។ បញ្ញវន្តខ្មែរក្នុងស្រទាប់នេះ យើងឃើញថាបានបញ្ចេញអត្ថបទភាគច្រើនទាក់ទងទៅនឹងរឿងល្បែងឬច្បាប់ឧបទេស។ ក្នុងចំណោមនោះផងដែរ អ្នកដែលត្រូវបានគេយកស្នាដៃរបស់គាត់មកចុះក្នុងទស្សនាវដ្ដីកម្ពុជសុរិយាច្រើនជាងគេគឺឧកញ៉ាសុត្តន្តប្រីជា ឥន្ទ ដែលអត្ថបទរបស់លោកជាច្រើនជាអត្ថបទច្បាប់ឧបទេស។
- អ្នកនិពន្ធឬម្ចាស់អត្ថបទដែលជាមន្ត្រីរាជការទូទៅ មានជាអាទិ៍គ្រូបង្រៀននិងមន្ត្រីនៅស្ថាប័នផ្សេងៗក្រៅពីពុទ្ធសាសនបណ្ឌិត្យ បានចុះផ្សាយអត្ថបទបានចំនួន១១៤ស្នាដៃ ត្រូវជា១៥% នៃស្នាដៃអក្សរសិល្ប៍ក្នុងកម្ពុជសុរិយា។ ប្រភេទអត្ថបទដែលក្រុមនេះបានសម្ដែងចេញ ភាគច្រើជារឿងព្រេងខ្លីៗនិងរឿងល្បើក។ អ្នកដែលបានបញ្ចេញអត្ថបទច្រើនជាងគេគឺ ផេង ជ្រីវ ដែលអត្ថបទរបស់លោកភាគច្រើនគឺជាស្នាដៃរឿងព្រេងបកប្រែ ពិសេសល្បើកឡាហ្វុងតែន។

- ចំណែកអ្នកនិពន្ធឬម្ចាស់អត្ថបទដែលយើងបានដាក់ឱ្យឋិតនៅក្នុងផ្នែកផ្សេងៗ ផ្សាយអត្ថបទអក្សរសិល្ប៍បានចំនួន៩៤ស្នាដៃ ដែលត្រូវជា១៣% នៃស្នាដៃអក្សរសិល្ប៍ក្នុងកម្ពុជសុរិយា។ ការដាក់ឱ្យនៅក្នុងផ្នែកផ្សេងៗ ក៏ព្រោះតែយើងមិនបានឃើញមានបញ្ជាក់ឈ្មោះម្ចាស់ស្នាដៃ អ្នករៀបរៀង អ្នកចងក្រង អ្នកបកប្រែ ឬអ្នកចម្លងឡើងវិញ នៅក្នុងអត្ថបទ។ ចំណែកអត្ថបទវិញច្រើនជារឿងព្រេង និងអត្ថបទស្រង់ពីសាស្ត្រាឬគម្ពីរផ្សេងៗដោយមិនបានបញ្ជាក់ឈ្មោះអ្នកដែលស្រង់។

  *សូមពិនិត្យមើលរូបខាងក្រោម៖*




រូបទី១ : ក្រាបសសរបង្ហាញចំនួនស្នាដៃអ្នកនិពន្ធឬម្ចាស់អត្ថបទ




រូបទី២ : ក្រាបផ្លិតបង្ហាញភាគរយស្នាដៃអ្នកនិពន្ធឬម្ចាស់អត្ថបទ

## ២.២- ប្រភពអត្ថបទអក្សរសិល្ប៍ចុះក្នុងទស្សនាវដ្ដីកម្ពុជសុរិយា

យើងបានបែងចែកប្រភពអត្ថបទអក្សរសិល្ប៍ក្នុងកម្ពុជសុរិយាជា៣ផ្នែករួមមាន អត្ថបទដែលស្រង់ពីកម្ពុជសុរិយាលេខចាស់ អត្ថបទដែលស្រង់ចេញពីច្បាប់/គម្ពីរ/ឯកសារផ្សេងៗ និងអត្ថបទដែលរៀបរៀង/បកប្រែ/និពន្ធថ្មី។ ផ្អែកតាមទិន្នន័យដែលស្រង់បាន យើងទទួលបានលទ្ធផលដូចខាងក្រោម៖

- អត្ថបទដែលស្រង់ពីកម្ពុជសុរិយាលេខចាស់ មានចំនួន១៤អត្ថបទ ស្មើនឹង២%នៃប្រភពអត្ថបទអក្សរសិល្ប៍ដែលចុះក្នុងទស្សនាវដ្ដីនេះ។ នៅក្នុងចំណោមនេះ អត្ថបទអក្សរសិល្ប៍មួយចំនួនដែលជាប្រភេទរឿងព្រេងនិងអត្ថបទអក្សរសិល្ប៍បែបសាសនា ដែលធ្លាប់បានចុះផ្សាយក្នុងលេខចាស់ឬឆ្នាំចាស់ ត្រូវបានគេយកមកចុះផ្សាយឡើងវិញច្រើនជាងអត្ថបទដទៃនៅក្នុងទស្សនាវដ្ដីលេខថ្មីឬឆ្នាំថ្មី។ មូលហេតុដែលយកអត្ថបទក្នុងលេខចាស់មកចុះផ្សាយជាថ្មីក្នុងលេខថ្មី យើងយល់ឃើញថា ទីមួយគឺដើម្បីផ្សាយអត្ថបទចាស់នោះទៅដល់អ្នកអានថ្មី ដែលទទួលជាវទស្សនាវដ្ដីលេខចាស់មិនបាន។ ទីពីរគឺដើម្បីបំពេញផ្ទៃទំព័រឬកម្រាស់ទំព័រនៃទស្សនាវដ្ដីលេខថ្មីនៅក្នុងករណីដែលកង្វះខាតឯកសារចុះផ្សាយ។
- អត្ថបទដែលស្រង់ចេញពីច្បាប់/គម្ពីរ/ឯកសារផ្សេងៗ មានចំនួន៣៨អត្ថបទ ដែលស្មើនឹង៥%នៃប្រភពអត្ថបទអក្សរសិល្ប៍សរុបក្នុងកម្ពុជសុរិយា។ អត្ថបទទាំងនេះជាអាទ៍ត្រូវបានគេស្រង់យកមកពីច្បាប់សាស្ត្រាស្លឹករឹត គម្ពីរបញ្ចតន្ត្រ ជាតកផ្សេងៗក្នុងពុទ្ធសាសនា ទស្សនាវដ្ដីពន្លឺពុទ្ធចក្រ និង

ឯកសារក្រុមជំនុំទំនៀមទម្លាប់ ជាដើម។ មូលហេតុដែលគេប្រមូលអត្ថបទអក្សរសិល្ប៍ពីប្រភពទាំងនេះមកចុះផ្សាយក្នុងទស្សនាវដ្ដីកម្ពុជសុរិយាអាចមកពីហេតុផលមួយចំនួនដូចជា បំណាងសង្គ្រោះឯកសារដែលប្រឈមឬរងនឹងការបាត់បង់(ពិសេសឯកសារសាស្ត្រាស្លឹករឹត) និងបំណងលើកកម្ពស់ឬបង្ហាញពីសារៈសំខាន់នៃពុទ្ធសាសនក្នុងសង្គមខ្មែរ(អត្ថបទក្នុងជាតកឬគម្ពីរពុទ្ធសាសនា)។

- អត្ថបទមួយផ្នែកទៀតគឺជាអត្ថបទរៀបរៀង/បកប្រែ/និពន្ធថ្មី ដែលមានចំនួន៦៣០អត្ថបទ ស្មើនឹង ៨៥%នៃប្រភពអត្ថបទអក្សរសិល្ប៍សរុបក្នុងកម្ពុជសុរិយា។ ប្រភពអត្ថបទដែលប្រសូតចេញពីការរៀបរៀង បកប្រែ ឬនិពន្ធថ្មីនេះ បានលើកយកប្រធានបទចម្រុះគ្នាមកលាតត្រដាងទៅតាមប្រភេទអ្នកនិពន្ធ ទំនោរ ទស្សនៈ និងបរិបទសង្គម។
- ចំណែកប្រភពអត្ថបទដែលមិនបានបញ្ជាក់ប្រភពច្បាស់លាស់មានចំនួន ៦២ ស្នាដៃ ស្មើនឹង៨%នៃប្រភពអត្ថបទអក្សរសិល្ប៍សរុបក្នុងទស្សនាវដ្ដីកម្ពុជសុរិយា។

*សូមពិនិត្យមើលរូបខាងក្រោម៖*




រូបទី៣ : ក្រាបសសរបង្ហាញចំនួនប្រភពអត្ថបទអ.សិ.ក្នុងកម្ពុជសុរិយា




រូបទី៤ : ក្រាបផ្លិតបង្ហាញ%នៃប្រភពអត្ថបទអ.សិ.ក្នុងកម្ពុជសុរិយា

## ២.៣- អត្តរូបនៃអត្ថបទអក្សរសិល្ប៍ដែលចុះក្នុងទស្សនាវដ្ដីកម្ពុជសុរិយា

រាប់ចាប់តាំងពីដើមកំណើតរហូតដល់ភាគខាងដើមនៃសតវត្សទី២០ ស្នាដៃអក្សរសិល្ប៍ខ្មែរស្ទើរតែទាំងស្រុងត្រូវបានស្តែងឡើងក្នុងមធ្យោបាយជាពាក្យកាព្យ(ពិសេសស្នាដៃអក្សរសិល្ប៍សម័យឧត្តុង្គ) ប្រកបដោយទំហំអត្ថបទវែងអន្លាយរាប់រយ រាប់ពាន់ល្បះ ដែលត្រូវបានគេសរសេរនៅលើសិលា សាស្ត្រាស្លឹករឹត ឬគម្ពីរផ្សេងៗ ហើយដែលខ្លឹមសារនៃស្នាដៃទាំងនោះច្រើនទាក់ទងទៅនឹងទ្រឹស្ដីព្រះពុទ្ធសាសនា។ លុះមកជិតដល់ពាក់កណ្ដាលទី១នៃសតវត្សទី២០ ស្នាដៃប្រលោមលោកពាក្យរាយក៏បានចាប់កំណើតឡើង ក្នុងនោះមានជាអាទិ៍បទនិពន្ធរឿង "ទឹកទន្លេសាប" របស់អ្នកនិពន្ធ គឹម ហាក់ ដែលត្រូវបានយកមកចុះផ្សាយនៅក្នុងទស្សនាវដ្ដីកម្ពុជសុរិយានាឆ្នាំ១៩៣៩ និងរឿង "កុលាបប៉ៃលិន" របស់លោក ញ៉ុក ថែម ដែលបានបោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្ដីកម្ពុជសុរិយានាឆ្នាំ១៩៤៣។

យោងតាមការធ្វើចំណាត់ថ្នាក់ទិន្នន័យ យើងបានចែកអត្តរូបនៃអត្ថបទអក្សរសិល្ប៍ក្នុងកម្ពុជសុរិយាជាបីផ្នែករួមមាន អត្ថបទពាក្យរាយ អត្ថបទកំណាព្យ និងអត្ថបទជាសុភាសិតឬពាក្យទំនឹមទំនៀម។

- អត្ថបទពាក្យរាយ មានចំនួន៥៨៧ស្នាដៃ ដែលស្មើនឹង៦៥%នៃអត្តរូបអត្ថបទអក្សរសិល្ប៍សរុបក្នុងទស្សនាវដ្ដីកម្ពុជសុរិយា។ អ្នកដែលប្រើប្រាស់ពាក្យរាយជាមធ្យោបាយសម្ដែងអត្ថបទច្រើនជាងគេគឺបណ្ដាអ្នកនិពន្ធឬម្ចាស់អត្ថបទនៃស្ថាប័នពុទ្ធសាសនបណ្ឌិត្យ មន្ត្រីរាជការទូទៅ និងបណ្ដាអ្នកនិពន្ធអ្នកស្រាវជ្រាវ ដែលអត្ថបទពាក្យរាយទាំងនោះច្រើនជាប្រភេទរឿងព្រេងឬប្រលោមលោកទំនើប។
- អត្ថបទកំណាព្យ មានចំនួន២១១ស្នាដៃ ដែលស្មើនឹង២៩%នៃអត្តរូបអត្ថបទអក្សរសិល្ប៍សរុបក្នុងទស្សនាវដ្ដីកម្ពុជសុរិយា។ បទកំណាព្យដែលយើងពិនិត្យឃើញអ្នកនិពន្ធឬម្ចាស់អត្ថបទលោកនិយមប្រើជាងគេមានកំណាព្យបទពាក្យប្រាំពីរ បទកាកគតិ បទព្រហ្មគីតិ បទពំនោល បទភុជង្គលីលា និងបទពាក្យប្រាំបួន។ ទន្ទឹមគ្នានេះ កំណាព្យបទទ្វេមាត្រឃើញមានការតែងនិពន្ធជា បទត្រីពិធព័ន្ធ បទរលកផ្ទប់ច្រាំង បទគោព័ទ្ធស្នឹងពាក្យប្រាំពីរ និងបទនាគកៀវក្រវាត់ ជាដើម។ យោងតាមទិន្នន័យយើងដឹងប្រាកដថា មធ្យោបាយតែងនិពន្ធដោយប្រើកំណាព្យស្ទើរតែទាំងស្រុងត្រូវបានគេយកទៅតែងនិពន្ធអត្ថបទប្រភេទរឿងល្បែងនិងច្បាប់ឧបទេស។[15]
- អត្ថបទជាសុភាសិតឬពាក្យទំនឹមទំនៀម មានចំនួន៥១ស្នាដៃ ដែលស្មើនឹង៦%នៃអត្តរូបអត្ថបទអក្សរសិល្ប៍សរុបក្នុងទស្សនាវដ្ដីកម្ពុជសុរិយា។ សុភាសិតឬពាក្យទំនឹមទំនៀមទាំងនេះ មួយចំនួនធំបានកើតឡើងនៅក្នុងតំណរយៈកាលនៃសង្គមខ្មែរតាំងពីបុរាណរៀងមក និងខ្លះទៀតមានប្រភពមកពីគម្ពីរពុទ្ធសាសនាតួយ៉ាងដូចជា ធម្មបទសុភាសិត និងជាតកសុភាសិត ជាដើម។ អត្ថបទសុភាសិតឬពាក្យទំនឹមទំនៀមដែលចងក្រងនិងចុះផ្សាយក្នុងទស្សនាវដ្ដីកម្ពុជសុរិយា មិនមានតែចំពោះសុភាសិតឬពាក្យទំនឹមទំនៀមដែលមានតែនៅក្នុងសង្គមខ្មែរប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានលើកយកសុភាសិតរបស់បណ្ដាប្រទេសឬរបស់ជនជាតិផ្សេងៗមកចែកជាចំណេះដឹងផងដែរដូចជា សុភាសិតបារាំងសែស សុភាសិតលាវ និងសុភាសិតអារាប់។[16] ខ្លឹមសារជារួមនៃសុភាសិតឬពាក្យទំនឹមទំនៀមទាំងនេះគឺបង្ហាញពីការអប់រំឬដុសខាត់ដោយបណ្ដុះប្រាជ្ញាស្មារតីមនុស្សឱ្យមានការខិតខំប្រឹងប្រែង ឧស្សាហ៍ព្យាយាម និងមានការប្រុងប្រយ័ត្នចំពោះកិច្ចការងារទាំងពួង។

(15) សូមមើលទិន្នន័យនៅឧបសម្ព័ន្ធ២, ២.៣- អត្តរូបនៃអត្ថបទអក្សរសិល្ប៍ក្នុងកម្ពុជសុរិយា : ចំណុច *"ខ- កំណាព្យ"*។

(16) សូមមើលទិន្នន័យនៅឧបសម្ព័ន្ធ២, ២.៣- អត្តរូបនៃអត្ថបទអក្សរសិល្ប៍ក្នុងកម្ពុជសុរិយា : ចំណុច *"គ- សុភាសិត/ពាក្យទំនឹមទំនៀម"*។

សូមពិនិត្យមើលរូបខាងក្រោម៖




រូបទី៥ : ក្រាបសសរបង្ហាញពីអត្តរូបអត្ថបទអ.សិ.ក្នុងកម្ពុជសុរិយា




រូបទី៦ : ក្រាបផ្ចិតបង្ហាញពីអត្តរូបអត្ថបទអ.សិ.ក្នុងកម្ពុជសុរិយា

## ២.៤- ប្រភេទអត្ថបទអក្សរសិល្ប៍ដែលចុះក្នុងទស្សនាវដ្ដីកម្ពុជសុរិយា

នៅក្នុងវិស័យអក្សរសិល្ប៍យើងគង់ពិនិត្យឃើញថា កម្ពុជសុរិយាបានប្រមូលផ្សាយនូវអត្ថបទអក្សរសិល្ប៍គ្រប់ប្រភេទដូចជាអក្សរសិល្ប៍សាសនា(ភាគច្រើនជាអក្សរសិល្ប៍ពុទ្ធសាសនា) រឿងព្រេង រឿងល្បែងច្បាប់ឧបទេស និងប្រលោមលោក ជាដើម មកចុះផ្សាយទៅតាមទំហំអត្ថបទនិងតាមលេខប្រចាំខែឬប្រចាំត្រីមាសរបស់ខ្លួន។ យោងតាមប្រភពទិន្នន័យដែលស្រង់បាន យើងទទួលបានលទ្ធផលដូចខាងក្រោម៖

- ប្រភេទរឿងព្រេង មានចំនួន២៥៦ស្នាដៃ ដែលស្មើនឹង៣៨%នៃប្រភេទអត្ថបទអក្សរសិល្ប៍សរុបក្នុងទស្សនាវដ្ដីកម្ពុជសុរិយា។ បណ្ដារឿងព្រេងទាំងនេះ ភាគច្រើនបំផុតត្រូវបានអ្នករៀបរៀង អ្នកបកប្រែ ឬអ្នកចងក្រងប្រើមធ្យោបាយពាក្យរាយដើម្បីកត់ត្រាចងក្រងទុកឱ្យមានជាសៀវភៅគោលឡើង ហើយដែលខ្លឹមសារនៃរឿងច្រើនបង្ហាញពីជីវភាពសាមញ្ញប្រចាំថ្ងៃរបស់ប្រជាកសិករ ពីទំនាស់វិបត្តិទាក់ទងរឿងទ្រព្យសម្បត្តិ ប្រពៃណី ជំនឿ ទំនៀមទម្លាប់ និងបង្ហាញពីប្រវត្តិទីស្ថាននានា ជាដើម។
- ប្រភេទសាសនា មានចំនួន១៤៧ស្នាដៃ ដែលស្មើនឹង២០%នៃប្រភេទអត្ថបទអក្សរសិល្ប៍សរុបក្នុងទស្សនាវដ្ដីកម្ពុជសុរិយា។ អត្ថបទអក្សរសិល្ប៍បែបសាសនានៅក្នុងទស្សនាវដ្ដីកម្ពុជសុរិយា ស្ទើរតែទាំងស្រុងទាក់ទងពុទ្ធសាសនា ដ្បិតថាមុនវត្តមានទស្សនាវដ្ដីកម្ពុជសុរិយាដល់ទៅជាង៤សតវត្សលទ្ធិជំនឿសាសនាក្នុងសង្គមខ្មែរបានជោគជាំខ្លាំងជាមួយនឹងពុទ្ធសាសនា ហើយថែមទាំងបានជះឥទ្ធិពលដល់និម្មិតកម្មតែងនិពន្ធស្នាដៃអក្សរសិល្ប៍របស់អ្នកនិពន្ធទាំងផ្នែកទម្រង់និងខ្លឹមសារ។ អត្ថបទអក្សរសិល្ប៍បែបសាសនាដែលមានចុះផ្សាយនៅក្នុងទស្សនាវដ្ដីកម្ពុជសុរិយា ដែលច្រើនជាបទនិពន្ធ អត្ថបទបកប្រែ ឬរៀបរៀងដោយព្រះសង្ឃ សមណសិស្ស-និស្សិត ព្រះគ្រូអាចារ្យ ដោយអត្ថបទមានប្រភពមកអំពីគម្ពីរឬជាតកនានា បានបង្ហាញពីតម្លៃអប់រំជាពិសេសផ្នែកសីលធម៌សង្គម ការបណ្ដុះឱ្យខិតខំធ្វើអំពើល្អជាកុសល ការចាប់យកធម៌ស្ងប់ជាត្រើយនៃសេចក្ដីសុខ និងការចេះតបស្នងគុណអ្នកមានគុណ ជាដើម។

- ប្រភេទរឿងល្បែង មានចំនួន៨ស្នាដៃ ដែលស្មើនឹង១%នៃប្រភេទអត្ថបទអក្សរសិល្ប៍សរុបដែលចុះក្នុងទស្សនាវដ្ដីកម្ពុជសុរិយា។ រឿងល្បែងទាំងនេះ សុទ្ធជាបទនិពន្ធរបស់កវីឬបញ្ញវន្តរបស់ខ្មែរដែលមានកំណើតកើតជានៅសម័យឧដុង្គ ហើយលោកបានចារនៅលើសាស្ត្រាស្លឹករឹតដោយមានលំនាំខ្លឹមសារនៃរឿងច្រើនទទួលឥទ្ធិពលពីពុទ្ធសាសនា។
- ប្រភេទច្បាប់ឧបទេស មានចំនួន១៥៣ស្នាដៃ ស្មើនឹង២១%នៃប្រភេទអត្ថបទអក្សរសិល្ប៍សរុបដែលចុះក្នុងទស្សនាវដ្ដីកម្ពុជសុរិយា។ ដំណាលគ្នានឹងសារៈសំខាន់នៃជំនឿសាសនានៅក្នុងសង្គមខ្មែរ ច្បាប់ឧបទេសក៏សុទ្ធតែមានតម្លៃជាប្រយោជន៍ចំពោះសង្គមមួយនេះដូចគ្នា។ ច្បាប់ឧបទេសដែលចុះក្នុងទស្សនាវដ្ដីកម្ពុជសុរិយា គឺចាស់ព្រឹទ្ធាចារ្យ កវីឬអ្នកនិពន្ធរៀមច្បងលោកបានចងក្រងនិពន្ធឡើងដោយឆ្លងកាត់ការពិនិត្យ អង្កេត និងបទពិសោធជីវិតដ៏ស៊ីជម្រៅ ហើយបន្សល់ទុកជាកំណាប់សីលធម៌ ជាប្រទីបទ្រោលបំភ្លឺផ្លូវ ជាច្បាប់បវេណី ដែលបានដុសខាត់ចិត្តគំនិតបងប្អូនប្រជាពលរដ្ឋពិសេសយុវជនដែលទម្លាប់អសកម្មឬមានការធ្វេសប្រហែស មានសីលធម៌-សុជីវធម៌មិនល្អ ឱ្យចេះភ្ញាក់រឭកកែប្រែខ្លួន ឱ្យមានស្មារតីស្នេហាជាតិ និងខិតខំរួបរួមគ្នាអភិវឌ្ឍប្រទេសជាតិឱ្យបានរីកចម្រើនឡើង។
- ប្រភេទប្រលោមលោក មានចំនួន១១ស្នាដៃ ដែលស្មើនឹង១%នៃប្រភេទអត្ថបទអក្សរសិល្ប៍សរុបដែលចុះក្នុងទស្សនាវដ្ដីកម្ពុជសុរិយា។ ការប្រើបញ្ញត្តិ "ប្រលោមលោក" នៅទីនេះយើងសំដៅយកអត្ថបទរឿងពាក្យរាយដែលបង្កប់ដោយមនោសញ្ចេតនាប្រលោមអារម្មណ៍អ្នកអាន អ្នកស្ដាប់។ ដោយសារតែទំហំអត្ថបទវែង ប្រលោមលោកដែលបានចុះផ្សាយក្នុងទស្សនាវដ្ដីកម្ពុជសុរិយាត្រូវគេចុះជាភាគៗទៅតាមលេខនិងឆ្នាំចេញផ្សាយ។ តួយ៉ាងដូចជារឿង "កុលាបប៉ៃលិន" របស់លោកញ៉ុក ថែម ដែលបានចុះផ្សាយក្នុងទស្សនាវដ្ដីនេះនៅឆ្នាំ១៩៤៣ ត្រូវនឹងឆ្នាំទី១៥ ពីលេខ៤រហូតដល់លេខ៨ទើបចប់។ មិនមានតែចំពោះប្រលោមលោកខ្មែរប៉ុណ្ណោះទេ ចំពោះរឿងប្រលោមលោកបរទេសក៏ត្រូវបានអ្នកនិពន្ធខ្មែរបកប្រែ ហើយយកមកផ្សាយដល់អ្នកអានតាមរយៈទស្សនាវដ្ដីកម្ពុជសុរិយានេះផងដែរ។ ប្រលោមលោកបរទេសបកប្រែដែលបានផ្សាយតួយ៉ាងមាន "រឿងសាមកុក" ដែលបកពីភាសាសៀមនៅឆ្នាំ១៩៣៣ដោយឧកញ៉ាវិបុលសេនាភាជ នូ កន និងបានចុះផ្សាយក្នុងទស្សនាវដ្ដីកម្ពុជសុរិយាចាប់ពីឆ្នាំទី២០ គ.ស.១៩៤៨ រហូតដល់ឆ្នាំទី៤៥ គ.ស.១៩៧៣ទើបចប់។
- ចំណែកអត្ថបទប្រភេទផ្សេងៗ មានចំនួន១៧០ស្នាដៃ ស្មើនឹង២៣%នៃប្រភេទអត្ថបទអក្សរសិល្ប៍សរុបដែលចុះក្នុងទស្សនាវដ្ដីកម្ពុជសុរិយា។ ស្នាដៃនេះសំដៅដល់ខ្លឹមសារប្រធានបទចម្រុះគ្នាដូចជា ការលើកខ្លឹមសារនិយាយពីវប្បធម៌ ទំនៀមទម្លាប់ប្រពៃណី ជីវភាពរស់នៅ បទវិភាគផ្សេងៗស្ដីពីប្រភពរឿង តួអង្គក្នុងអក្សរសិល្ប៍ និងជីវប្រវត្តិសង្ខេបអ្នកនិពន្ធ ជាដើម។

*សូមពិនិត្យមើលរូបខាងក្រោម៖*




រូបទី៧ : ក្រាបសសរបង្ហាញពីប្រភេទអត្ថបទអ.សិ.ក្នុងកម្ពុជសុរិយា




រូបទី៨ : ក្រាបផ្ចិតបង្ហាញពីប្រភេទអត្ថបទអ.សិ.ក្នុងកម្ពុជសុរិយា

## ៣- តួនាទីទស្សនាវដ្ដីកម្ពុជសុរិយាក្នុងការលើកកម្ពស់អក្សរសិល្ប៍ខ្មែរ

### ៣.១- តួនាទីផ្ដល់ឱកាសឱ្យអ្នកនិពន្ធបានចេញផ្សាយស្នាដៃ

នៅចុងសម័យឧដុង្គ ពេលដែលប្រទេសកម្ពុជារងការគាបសង្កត់ធ្វើទុក្ខបុកម្នេញខ្លាំងពីប្រទេសក្បែរខាងពីរដែលមានសៀមនិងអណ្ណាម ព្រះរាជាខ្មែរព្រះបាទអង្គឌួងបានទ្រង់ស្វែងយល់ថាត្រូវរកជំនួយពីប្រទេសមហាអំណាចណាមួយនៅអឺរ៉ុបឱ្យមកជួយធ្វើអន្តរាគមន៍នៅកម្ពុជា។ ការណ៍នេះ ព្រះអង្គបានថ្វាយព្រះរាជសារសម្ងាត់ជូនព្រះចៅអធិរាជបារាំងណាប៉ូឡេអុងទី៣ ក្នុងបំណងមិត្តភាពនិងអាណាព្យាបាលភាពលើកម្ពុជាដើម្បីការពារឬទប់ស្កាត់ឥទ្ធិពលរបស់សៀមនិងអណ្ណាម។ ប៉ុន្តែព្រះរាជបំណងរបស់ទ្រង់មិនបានសម្រេចឡើយ ដរាបមកដល់រជ្ជកាលបុត្ររបស់ព្រះអង្គគឺរជ្ជកាលព្រះបាទនរោត្តម ទើបព្រះរាជបំណងនោះបានសម្រេចឡើយ។ បារាំងបានធ្វើជាអាណាព្យាបាលភាពគ្រប់គ្រងប្រទេសកម្ពុជាអស់រយៈពេល៩០ឆ្នាំ (គ.ស.១៨៦៣-១៩៥៣) ដែលក្នុងដំណាក់កាលនេះ ប្រទេសអឺរ៉ុបមួយនេះបានពាំនាំមកឱ្យកម្ពុជានូវការសិក្សាស្រាវជ្រាវពីវប្បធម៌ អរិយធម៌ ភាសា ប្រវត្តិសាស្ត្រ សិល្បៈ បុរាណវិទ្យា កំណែប្រែប្រព័ន្ធរដ្ឋបាល ពង្រឹងប្រព័ន្ធអប់រំ និងរាប់ទាំងការបង្កើតនូវរោងពុម្ពដើម្បីបោះពុម្ពផ្សាយឯកសារ ជាដើម។

នៅភាគខាងដើមនៃសតវត្សទី២០ ខណៈពេលដែលរោងពុម្ពនៅស្រុកខ្មែរដែលផ្ដួចផ្ដើមបង្កើតឡើងដោយរដ្ឋអំណាចអាណាព្យាបាលមិនទាន់សម្បូរនៅឡើយ គឺទស្សនាវដ្ដីកម្ពុជសុរិយានេះហើយដែលជាទស្សនាវដ្ដីភាសាខ្មែរដំបូងគេ ដែលបានផ្ដល់លទ្ធភាពឱ្យអ្នកនិពន្ធខ្មែរមានឱកាសបានចេញផ្សាយស្នាដៃប្រលោមលោករបស់ខ្លួនឬស្នាដៃអក្សរសិល្ប៍ទៅកាន់អ្នកអាន។ នៅក្នុងដំណាក់កាលដែលសង្គមខ្មែរឋិតក្រោមអាណាព្យាបាលរបស់បារាំង(គ.ស.១៨៦៣-១៩៥៣) យើងពិនិត្យឃើញថាស្នាដៃអក្សរសិល្ប៍ដែលបានផ្សាយក្នុងទស្សនាវដ្ដីនេះមិនមានខ្លឹមសារនិយាយប៉ះពាល់ឬរិះគន់ដល់រដ្ឋអំណាចនេះឡើយ។ ស្នាដៃទាំងនោះមានជាអាទិ៍ដូចជាប្រលោមលោក *"រឿងទឹកទន្លេសាប"* របស់អ្នកនិពន្ធ គឹម ហាក់ ដែលត្រូវបាន

ចេញផ្សាយនៅក្នុងទស្សនា វដ្តីកម្ពុជសុរិយាឆ្នាំ១៩៣៩ ហើយ *"រឿងកុលាបប៉ៃលិន"* របស់អ្នកនិពន្ធ ញ៉ុក ថែម ក៏ត្រូវបានចុះផ្សាយក្នុង ទស្សនាវដ្តីកម្ពុជសុរិយាឆ្នាំទី១៥ នាគ្រិស្តរាជ១៩៤៣ ផងដែរ។[17]

## ៣.២- តួនាទីផ្តល់ការកម្សាន្តនិងចំណេះដឹងស្តីពីអក្សរសិល្ប៍

ទស្សនាវដ្តីកម្ពុជសុរិយាបានចូលរួមចំណែកយ៉ាងសកម្មនៅក្នុងការផ្តល់ការកម្សាន្ត ចំណេះដឹង និងអប់រំស្តីពីអក្សរសិល្ប៍ទៅដល់អ្នកអានទាំងឡាយ។ ដ្បិតថាអំណានអក្សរសិល្ប៍ក៏ជាមធ្យោបាយកម្សាន្តដ៏សំខាន់បំផុតមួយផ្នែកបញ្ញាស្មារតី ដែលបានផ្តល់ដល់អ្នកអាននូវអារម្មណ៍កម្សាន្តឬមនោសញ្ចេតនាចម្រុះបែប។ ដើរទន្ទឹមគ្នានឹងតួនាទីកម្សាន្ត អក្សរសិល្ប៍នៅក្នុងកម្ពុជសុរិយាក៏បានរួមចំណែកផ្តល់ចំណេះដឹង[18] ជាច្រើនដល់អ្នកអានអំពីសាសនា ជំនឿ ទំនៀមទម្លាប់ វប្បធម៌ អរិយធម៌ជីវភាពរស់នៅប្រចាំថ្ងៃ ប្រវត្តិសាស្ត្រ សង្គម ឬស្នេហា។ល។ និងថែមទាំងបានរួមចំណែកអប់រំអ្នកអានលើផ្នែកសីលធម៌ឱ្យមានអាកប្បកិរិយាស្លូតបូត មានការឧស្សាហ៍ព្យាយាម មានការប្រុងប្រយ័ត្ន ស្គាល់ល្អអាក្រក់ និងបណ្តុះស្មារតីមនុស្សឱ្យស្រឡាញ់សន្តិភាព ចូលរួមសាងឬប្រកាន់ខ្ជាប់តែទង្វើល្អសុចរិតត្រឹមត្រូវ ជាដើម។

## ៣.៣- តួនាទីអភិរក្ស ថែរក្សា និងលើកកម្ពស់វឌ្ឍនភាពអក្សរសិល្ប៍ខ្មែរ

បន្ថែមពីលើតួនាទីផ្តល់ឱកាសឱ្យអ្នកនិពន្ធបានផ្សាយស្នាដៃ តួនាទីផ្តល់ការកម្សាន្តនិងចំណេះដឹងស្តីពីអក្សរសិល្ប៍ ទស្សនាវដ្តីកម្ពុជសុរិយាក៏បានដើរតួនាទីសំខាន់មួយទៀតគឺ តួនាទីជាអ្នកអភិរក្សឬថែរក្សាលើកកម្ពស់និងអភិវឌ្ឍស្នាដៃអក្សរសិល្ប៍ខ្មែរផងដែរ។ តួនាទីជាអ្នកអភិរក្សឬថែរក្សា ព្រោះថាទស្សនាវដ្តីកម្ពុជសុរិយាគឺជាឃ្លាំងដែលប្រមូលរាល់ស្នាដៃអក្សរសិល្ប៍ ជាពិសេសបណ្តាបទនិពន្ធឬស្នាដៃចាស់ៗដែលបានរងនូវការខូចខាតដោយសារចំណាស់ភាពនៃសម្ភារៈកត់ត្រា ការបំផ្លិចបំផ្លាញពីសត្វល្អិតឬអាកាសធាតុ ឬស្នាដៃដែលស្ទើរតែបាត់បង់ទៅហើយនោះមកថែរក្សា ជួសជុល និងតម្កល់ទុកជាក្រាំងឯកសារគោលឱ្យបិតបេរគង់វង្សឡើងវិញ។ យើងពិនិត្យឃើញមានជាអាទិ៍នូវប្រភេទសាស្ត្រាល្បែងមួយចំនួន ដែលអ្នកនិពន្ធជាន់ចាស់លោកបានចារក្នុងសាស្ត្រាស្លឹករឹត ហើយក្រុមការងារឬបុគ្គលិកពុទ្ធសាសនបណ្ឌិត្យបានប្រមូលត្រួតពិនិត្យផ្ទៀងផ្ទាត់ និងរៀបចំចម្លងឡើងវិញក្នុងបំណងរក្សាទុកសម្បត្តិទាំងនេះនិងធ្វើការបោះពុម្ពផ្សាយជាស្នាដៃដើម្បីបានជាប្រយោជន៍ចំពោះខេមរជនទូទៅ។ តួនាទីជាអ្នកលើកកម្ពស់វឌ្ឍនភាពអក្សរសិល្ប៍ព្រោះទស្សនាវដ្តីកម្ពុជសុរិយាបានជំរុញបន្តដង្ហើមអក្សរសិល្ប៍ខ្មែរឱ្យនៅតែបន្តវត្តមានទៅដល់អ្នកអានជានិច្ច បើទោះបីជាបរិបទស្រុកទេសកំពុងជាប់នៅក្រោមនឹមនៃការត្រួតត្រារបស់បរទេសម្តេចក្តី។ ខ្លឹមសារនៃចំណុចនេះទៀតសោត ទស្សនាវដ្តីមួយនេះក៏ជាភស្តុតាងចង្អុលបង្ហាញឱ្យឃើញពីដំណើររបត់ថ្មីនៃបម្លាស់ប្តូរទម្រង់តែងនិពន្ធស្នាដៃអក្សរសិល្ប៍នៅក្នុងសង្គមខ្មែរផងដែរ។

---

(17) សូមមើលតារាងឧបសម្ព័ន្ធ២, ប្រភេទអត្ថបទអក្សរសិល្ប៍ក្នុងកម្ពុជសុរិយា : *"ង- ប្រភេទប្រលោមលោក"*។

(18) សូមបញ្ជាក់ផងដែរថាចំណេះដឹងស្តីពីអក្សរសិល្ប៍ដែលធ្លាប់មានចុះក្នុងទស្សនាវដ្តីកម្ពុជសុរិយាពីឆ្នាំដំបូងរហូតដល់ចុងទសវត្សឆ្នាំ៥០ នៅមិនទាន់មានជាលក្ខណៈចំណេះដឹងបែបទ្រឹស្តីអក្សរសិល្ប៍ ការវិភាគឬសិក្សាស៊ីជម្រៅលើស្នាដៃអក្សរសិល្ប៍នេះនៅឡើយទេ។ នេះមកអំពីទិដ្ឋភាពនៃការសិក្សាអប់រំនៅអំឡុងពេលនោះមិនទាន់មានមុខវិជ្ជាទ្រឹស្តីអក្សរសិល្ប៍ នៅឡើយ ហើយមហាវិទ្យាល័យអក្សរសាស្ត្រ-មនុស្សសាស្ត្រ ក៏ទើបតែចាប់កំណើតឡើងនៅក្រុងភ្នំពេញនាឆ្នាំ១៩៦០ តាមរយៈសាកលភូមិន្ទខ្មែរ ដែលសព្វថ្ងៃនេះមានឈ្មោះហៅថាសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

## ៤- សេចក្ដីសន្និដ្ឋាន

យោងតាមខ្លឹមសារដែលបានសិក្សាបង្ហាញខាងលើ យើងឃើញថាទស្សនាវដ្ដីកម្ពុជសុរិយាពិតជាបានរួមចំណែកយ៉ាងធំធេងនៅក្នុងការលើកកម្ពស់អក្សរសិល្ប៍ខ្មែរ។ ស្មេរសូមកោតសរសើរនិងគោរពដឹងគុណជាអនេកប្រការចំពោះអ្នកប្រាជ្ញ បណ្ឌិត កវី អ្នកនិពន្ធ និងរួមទាំងបណ្ដាបញ្ញវន្តរៀមច្បងទាំងឡាយដែលលោកបានខិតខំនិពន្ធ ចងក្រង និងបន្សល់ជាស្នាដៃទុកសម្រាប់ជាប្រយោជន៍ចំពោះជនរួមជាតិជំនាន់ក្រោយ។ ជាមួយគ្នានេះ ស្មេរក៏សូមកោតសរសើរខ្ពស់ចំពោះថ្នាក់ដឹកនាំនិងក្រុមការងារនៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យទាំងអស់ ដែលតាំងអំពីដើមរៀងមក លោកបានខិតខំយ៉ាងសកម្មនៅក្នុងកិច្ចការប្រមូល រៀបរៀង បកប្រែ ស្រាវជ្រាវ និងនិពន្ធចងក្រងឯកសារទាំងឡាយ ហើយសកម្មភាពទាំងនេះបានផ្ដល់នូវលទ្ធភាពឱ្យយើងបានសិក្សារៀនសូត្រនិងទទួលចំណេះដឹងយ៉ាងច្រើនស្ដីពីអក្សរសិល្ប៍ វប្បធម៌ ជំនឿ ប្រពៃណី ទំនៀមទម្លាប់ ប្រវត្តិសាស្ត្រ និងសិល្បៈ ជាដើម។ ទន្ទឹមនឹងការមានឯកសារនិងទស្សនាវដ្ដីដ៏មានសារៈសំខាន់នេះ ស្មេររំពឹងថាបណ្ដាខេមរជនទាំងឡាយ ជាពិសេសសិស្ស-និស្សិតដែលរៀនជំនាញអក្សរសាស្ត្រខ្មែរ គួរតែនាំគ្នាអាននិងសិក្សាស្រាវជ្រាវអត្ថបទទាំងឡាយក្នុងទស្សនាវដ្ដីនេះ។ បន្ថែមពីលើនេះ យើងដែលជាយុវជននិងធនធានជំនាន់ក្រោយ ក៏គួរនាំគ្នាពិនិត្យមើលគំរូល្អៗទាំងឡាយរបស់រៀមច្បងយើង ដោយចូលរួមតែងនិពន្ធ សិក្សាស្រាវជ្រាវលើប្រធានបទចម្រុះបែប និងរួមគ្នាបន្តគាំទ្រទស្សនាវដ្ដីកម្ពុជសុរិយានេះឱ្យនៅតែគង់វង្សមានជារៀងដរាបទៅនៅក្នុងសង្គមកម្ពុជាយើង។

# ឯកសារពិគ្រោះ

- យឹង ហុកឌី, (២០០៧), *អក្សរសិល្ប៍ខ្មែរសតវត្សទី២០ កវីនិពន្ធនិងកម្រងអត្ថបទ*, គ្រឹះស្ថានបោះពុម្ពផ្សាយអង្គរ : ភ្នំពេញ។
- ពុទ្ធិកសមាគម-មជ្ឈមណ្ឌលកម្ពុជរដ្ឋ, (១៩៦១) *ទស្សនាវដ្ដីពន្លឺពុទ្ធចក្រ* : វត្តឧណ្ណាលោម ក្រុងភ្នំពេញ។
- ព្រះរាជបណ្ណាល័យ, (១៩២៦-១៩៤២), *ទស្សនាវដ្ដីកម្ពុជសុរិយា*, បោះពុម្ពផ្សាយដោយរោងពុម្ពរាជការ គូវែរណើម៉ង្គ, រោងពុម្ពអាល់បែរ : ភ្នំពេញ។
- វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, (១៩៩៤-២០០៦ និង ២០១៤-២០១៩), *ទស្សនាវដ្ដីកម្ពុជសុរិយា*, បោះពុម្ពផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ : ភ្នំពេញ។
- វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, (១៩៤៣-១៩៧៤), *ទស្សនាវដ្ដីកម្ពុជសុរិយា*, បោះពុម្ពផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ : ភ្នំពេញ។
- វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, (២០០៦), *ប្រវត្តិពុទ្ធិកសិក្សា*, រក្សាសិទ្ធគ្រប់យ៉ាង : ភ្នំពេញ។
- វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, (១៩៦៧), *វចនានុក្រមខ្មែរ* ភាគ១-២ (បោះពុម្ពគ្រាទី៥), បោះពុម្ពផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ : ភ្នំពេញ។
- សមាគមមិត្តសាលាបាលីកម្ពុជរដ្ឋ, (១៩៥៥), *ទស្សនាវដ្ដីមិត្តសាលាបាលី*, វត្តលង្ការ សង្កាត់លេខ៦ ក្រុងភ្នំពេញ។
- The Center for Khmer Studies, Reyum Institute & The Toyota Foundation, (December 2002), *PUBLISHING IN CAMBODIA*, Preliminary Edition : Phnom Penh.
- https://m.wikisource.កម្ពុជសុរិយា
- https://m.youtube.com/watch?v=xS8jDr2Io0E